ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១

# សេចក្ដីប្រកាសព័ត៌មាន

ថ្ងៃនេះ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើភាពអាចទទួលយកបាន នៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៣។

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ ហើយតាមរយៈដីកាសម្រេចមួយផ្សេងទៀត បានសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលនៅសេសសល់ អនុលោមតាមវិធាន ២៣ស្ទួន នៃវិធានផ្ទៃក្នុង។

បន្ទាប់ពីអង្គជំនុំជម្រះបានចេញសេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ កាលពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះបានពិនិត្យលើបណ្ដឹងឧទ្ធរណ៍ ដែលដាក់ដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលពាក្យសុំរបស់ពួកគាត់ត្រូវបានច្រានចោលដោយដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

នៅក្នុងសំណុំរឿង ០០៣ មានប្រជាជនចំនួន ៦៤៦ នាក់ បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចាប់តាំងពីពេលចាប់ផ្ដើមកិច្ចស៊ើបសួរ (កថាខណ្ឌ ៥)។

នៅក្នុងសេចក្ដីពិចារណារបស់ខ្លួន អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆន្ទថា បណ្ដឹងឧទ្ធរណ៍អាចទទួលយកបាន (កថាខណ្ឌ ៣៣) ហើយបានបញ្ជាក់បំភ្លឺអំពីគោលការណ៍គតិយុត្តិនានាពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខ អ.វ.ត.ក (កថាខណ្ឌ ៣៤-៤១)។

ប៉ុន្តែ អង្គបុរេជំនុំជម្រះមិនអាចរកបានសម្លេងគាំទ្រពីចៅក្រមយ៉ាងតិចចំនួនបួនរូប ដើម្បីសម្រេចទៅលើអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍នៅក្នុងសំណុំរឿងនេះបានឡើយ (កថាខណ្ឌ ៤២)។

ចៅក្រមជាតិសម្រេចថា ពាក្យសុំទាំងអស់ក្នុងសំណុំរឿង ០០៣ គួរត្រូវបានបដិសេធចោល ដោយសារតែចៅក្រមជាតិមានទស្សនៈថា “ដីកាដំណោះស្រាយទាំងពីរ មានតម្លៃស្មើគ្នា និងមានសុពលភាពដូចគ្នា” និងថា “គួររក្សាទុកសំណុំរឿង ០០៣ ប្រឆាំងជនត្រូវចោទ មាស មុត នៅក្នុងបណ្ណសាររបស់ អ.វ.ត.ក” (កថាខណ្ឌ ៤៣-៤៦)។

ចៅក្រមអន្តរជាតិបានត្រួតពិនិត្យលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ នៅចុងបញ្ចប់ ចៅក្រមអន្តរជាតិសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន លើភាពអាចទទួលយកបាន តាមមូលដ្ឋាន ១(១) និង ១(៣) គឺថាជនរងគ្រោះចំនួនប្រាំរូបបន្ថែម គួរត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៣ (កថាខណ្ឌ ១១១)។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ អាចស្វែងរកបាននៅលើគេហទំព័រ៖
https://eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D269_4_KH.PDF

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

ឯកឧត្តម នេត្រ ភក្ត្រា
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ
ទូរស័ព្ទលេខ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh